## អនុក្រឹត្យ លេខ : ៤៧ អនក្រ.បក
## ស្តីពីការបង្កើតទិវាគ្រូបង្រៀន

===

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ ន.ស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១០-៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១០-៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី ។

### សំរេច

**មាត្រា ១.**_កំណត់យកថ្ងៃ០៥ ខែតុលា រៀងរាល់ឆ្នាំ ធ្វើជាទិវាជាតិ ឈ្មោះថា « ទិវាគ្រូបង្រៀន » នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.**_ក្រសួងអប់រំយុវជននិងកីឡា មានភារកិច្ចអប់រំសិស្ស - និស្សិត និងសង្គម អំពីអត្ថន័យនៃ « ទិវាគ្រូបង្រៀន » និង បំផុសការអនុវត្តន៍អោយបានល្អនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣.**–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកី
រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀ
ខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ១៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី

ហត្ថលេខានិងត្រា

**អ៊ុង ហួត** **ហ៊ុន សែ**

* * *

## អនុក្រឹត្យ លេខ : ៤៨ អនក្រ.បក

## ស្តីពីការប្រើប្រាស់គណនីឯកជនភាពបន្ទុកម្ចាស់ហាក្ញាសាធារណៈ សំរាប់ទូទាត់សងថ្លៃដីធ្លី-ផ្ទះសំបែងប្រជារាស្ត្រដែលមានការប៉ះពាល់ ដល់គំរោងសាងសង់ស្ពានឆ្លងទន្លេមេគង្គ ខេត្តកំពង់ចាម និង សំណង់នានា

## រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី តែងតាំង រាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម លេ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
– បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោ ព្រះរាជក្រម លេខ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤